តុលាការកំពូល និងមហាអយ្យការ
អមតុលាការកំពូល
លេខ ៨៥ .តកក.សនវ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ប្រធានតុលាការកំពូល

**ជម្រាបមក**

**លោកប្រធានតុលាការក្រុងភ្នំពេញ**

**កម្មវត្ថុ:** អំពីការសុំគោលការណ៍អនុវត្តមាត្រា២៥ នៃក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យាលើរឿងក្តីរដ្ឋប្បវេណី ។

**យោង:** លិខិតលេខ ១៦៣ រប ៩២១-០៦ ចុះថ្ងៃ០៧-០៣-២០០៦ របស់តុលាការក្រុងភ្នំពេញ ។

ខ្ញុំសូមជម្រាបលោកថា៖

-ការដែលតុលាការមិនចាត់ការលើសំណុំរឿងព្រហ្មទណ្ឌលើសពី៣ឆ្នាំ ចំពោះបទល្មើសមជ្ឈិម និងលើសពី ១០ ឆ្នាំ ចំពោះបទល្មើសឧក្រិដ្ឋ ហើយចាត់ទុកជាហួសអាយុកាល ហើយអយ្យការរំលត់បណ្តឹងអាជ្ញាចោលនោះ ជាការមិនត្រឹមត្រូវឡើយ ពីព្រោះថា៖

១-នេះជាកំហុសរបស់ចៅក្រមដែលកាន់រឿងនេះ ដែលត្រូវទទួលការចោទប្រកាន់ពីដើមបណ្តឹងរដ្ឋប្បវេណី ឬពីម្ចាស់បណ្តឹងអាជ្ញា ។

២-បណ្តឹងអាជ្ញាត្រូវរំលត់ តែនៅពេលណាជនប្រព្រឹត្តបទល្មើសស្លាប់តែប៉ុណ្ណោះ រិតតែមិនត្រឹមត្រូវទៅទៀត នៅពេលដែលតំណាងអយ្យការជាម្ចាស់បណ្តឹងអាជ្ញា ហើយទៅរំលត់បណ្តឹងអាជ្ញាចោល ព្រោះតែចៅក្រមទុកសំណុំរឿងចោលមិនចាត់ការឱ្យហួសពី ៣ ឬ ១០ឆ្នាំ ដែលគ្មានច្បាប់ចែងឱ្យធ្វើដូច្នេះទេ ។

-ចំពោះមាត្រា២៥ នៃក្រឹត្យច្បាប់ ៣៨ មានន័យច្បាស់លាស់ណាស់ផុតអាជ្ញាយុកាល កាលបើភាគីដើមបំណុលមិនប្តឹងទាមទារក្នុងអំឡុង៥ឆ្នាំ ។ មាត្រា ២៦ រិតតែបញ្ជាក់ច្បាស់លាស់ទៅទៀត ។

អាស្រ័យហេតុនេះ សូមលោកប្រធានតុលាការចាត់ការអនុវត្តឱ្យត្រឹមត្រូវឡោមច្បាប់ ។

សូម លោកប្រធាន ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៦

**ឌិត មុន្ធី**